-បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១ .- ត្រូវបានបង្កើតស្រុកគាស់ក្រឡ ដោយកាត់យកភូមិភាគស្រុកមួយចំណែកពីស្រុកមោងឫស្សី ។

មាត្រា ២ .- ស្រុកគាស់ក្រឡ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .- ស្រុកគាស់ក្រឡ ត្រូវបានបង្កើតឃុំចំនួន ០៦ គឺឃុំធិបតី ឃុំគាស់ក្រឡ ឃុំហប់ ឃុំដូនបា ឃុំព្រះផុស និងឃុំឆ្នាល់មាន់ ។

មាត្រា ៤ .- ស្រុកគាស់ក្រឡ ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាល ដូចខាងក្រោម :

-ខាងជើង ទល់នឹងស្រុកបាណន់ និង ស្រុកសង្កែ ខេត្តបាត់ដំបង ។

-ខាងត្បូង ទល់នឹងស្រុកវាលវែង ខេត្ត ពោធិ៍សាត់ ។

-ខាងកើត ទល់នឹងស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

-ខាងលិច ទល់នឹងស្រុកសំឡូត និង ស្រុកបាណន់ ខេត្តបាត់ដំបង ។

មាត្រា ៥ .- ទីតាំងស្នាក់ការស្រុកគាស់ក្រឡ ស្ថិតនៅក្នុងឃុំគាស់ក្រឡ ។

មាត្រា ៦ .- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៣២ អនក្រ.បក

## ស្តីពី

## វិសោធនកម្មមាត្រា ១៤ និង ១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះអតីតយុទ្ធជនកងយោធពលខេមរភូមិន្ទ

-ឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-ឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-ឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-ឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនកងយោធពលខេមរភូមិន្ទ

-ឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.តត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ

-ឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

-ឃើញអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១ .-**

មាត្រា៤ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ត្រូវបានកែសម្រួលដូចតទៅ :

**មាត្រា៤ថ្មី** : យោធិនទាំងឡាយ ដែលមានគ្រប់លក្ខខណ្ឌត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែហើយ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ ជំពូកទី១ នៃព្រះរាជក្រមលេខ០៧ ន.ស.៩៤ ចុះថ្ងៃទី

២៨ ខែ តុលា ឆ្នាំ ១៩៩៤ ។ ក្រៅពីទទួលរបបសោធននិវត្តន៍ ជាប្រចាំខែដូចដែលបានបញ្ជាក់ក្នុងប្រការ ទី១ ខាងលើ យោធិនទាំងពីរនេះ ត្រូវបានទទួលរបបអនុគ្រោះដូចខាងក្រោម :

១-អ្នកនៅក្នុងបន្ទុកដែលត្រូវទទួលមរតកគាត់ អាចមានសិទ្ធិទទួលរបបជួយនៅពេលបាត់បង់ជីវិត ។

២-ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ឬវីរជនដែលមានស្នាដៃពិសេសក្នុងការការពារ ត្រូវ បានរៀបចំពិធីបុណ្យសពតាមពិធីយោធា និងបាញ់គ្រាប់កាំភ្លើង ។

៣-ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងអាជ្ញាធរមានសមត្ថកិច្ច មានភារកិច្ចពិនិត្យលទ្ធភាព ជួយរកការងារធ្វើអោយយោធិនពិការ ឬជនបាត់បង់សមត្ថភាពការងារ ដែលនៅមានលទ្ធភាពធ្វើការងារបន្ត បាន ដោយផ្អែកទៅតាមសមត្ថភាព និងជំនាញរបស់សាមីខ្លួន ។

**មាត្រា ២ .-**

មាត្រា១៤ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៦ ត្រូវបានកែតម្រូវដូច តទៅ :

**មាត្រា១៤ថ្មី** :- ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិ ត្រូវត្រៀមបញ្ជីឈ្មោះយោធិនចូលនិវត្តន៍ យោធិន បាត់បង់សមត្ថភាពការងារ និងយោធិនមិនបានបំពេញលក្ខខណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សមត្ថភាពការងារ ជូនក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដើម្បីរៀបចំថវិកាក្នុងការបើកផ្ដល់ សោធននិវត្តន៍ សោធនបាត់បង់សមត្ថភាពការងារ និងយោធិនមិនបានបំពេញលក្ខខណ្ឌចូលនិវត្តន៍ ឬចូល បាត់បង់សមត្ថភាពការងារ ។

-ការត្រួតត្រា និងបើកផ្ដល់របបសោធននិវត្តន៍ និងយោធិនបាត់បង់សមត្ថភាពការងារប្រចាំខែ និង បើករបបធានារ៉ាប់រងសង្គមនៅពេលនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានជំងឺ ឬគ្រោះថ្នាក់ និងប្រាក់ ធានារ៉ាប់រងសង្គមសំរាប់គ្រួសារក្នុងករណីមរណភាពរបស់និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ ជាសមត្ថ កិច្ចរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រហូតដល់ពេលចេញបានសៀវភៅសោធន ។

-ក្រសួងការពារជាតិមានភារកិច្ចបើកប្រាក់ឧបត្ថម្ភ១លើក ជូនយោធិននិវត្តជន ជនបាត់បង់សមត្ថភាព ការងារ និងយោធិនមិនបានបំពេញលក្ខខណ្ឌចូលនិវត្តន៍ ឬជនបាត់បង់សមត្ថភាពការងារ នៃកងយោធពល ខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា៥ ចំណុចលេខ១ មាត្រា៦ មាត្រា១១ ចំណុចលេខ១ មាត្រា១៣ នៃច្បាប់ ស្ដីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពល ខេមរភូមិន្ទ មុនពេលផ្ទេរទៅអោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

**មាត្រា ៣ .-**

មាត្រា១៥ នៃអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៧ ខែ មីនា ឆ្នាំ ១៩៩៦ ត្រូវបានកែតម្រូវ ដូចតទៅ :

**មាត្រា១៥ថ្មី** :- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច-ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និង

www.pheakdeylaw.com

អតីតយុទ្ធជន និងអភិបាលខេត្ត-ក្រុង ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថ និងចុះហត្ថលេខានេះតទៅ ។

**មាត្រា ៤ -.**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវ ទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា ព្រះហស្តលេខា

ទៀ បាញ់ ស៊ីសុវត្ថិ ស៊ីរីរ័ត្ន

***

## អនុក្រឹត្យ លេខ ៣៣ អនក្រ.បក

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិ សំរបសំរួលសាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សានានា នៃព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៩៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល